**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៤២០/៣០-០៤-២០១៤

**សាលដីកា**

លេខ:១៩ក្រIVសស/១៦-១០-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស / រកម /០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

## <u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

## <u>តំណាងមហាអយ្យការ</u>

លោក [redacted]

## <u>ក្រឡាបញ្ជីសវនាការ</u>

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ៤២០ ចុះថ្ងៃទី៣០-០៤-២០១៤ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] លីថូ ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនិងទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស)ប្រពន្ធឈ្មោះ [redacted] មានកូន០៥នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី ២៣-៩-២០១៣ ។ (ដើមបណ្តឹងឧទ្ធរណ៍)

២-ឈ្មោះ [redacted] សត្ថារិត ហៅ [redacted] សុជារិទ្ធ ភេទប្រុស អាយុ ៥៨ឆ្នាំ។

ជាប់ចោទពីបទ:ឆបោក ប្រព្រឹត្តនៅភូមិក្រសាំង ឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង កាលពីថ្ងៃទី ២៨-១០-២០១០ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧និង៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៤០៧

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៦០ឆ្នាំ ទីលំនៅ [redacted] ។

## ៦រឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទី២៨-១០-២០១០ ជនជាប់ចោទឈ្មោះ [redacted] លីថូ បានទៅផ្ទះរបស់ឈ្មោះ [redacted] វន់ និងឈ្មោះ [redacted] មាស ស្ថិតនៅភូមិក្រសាំង ឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង និយាយលួងលោមឈ្មោះ [redacted] មាស និងឈ្មោះ [redacted] វន់ ថា គេមានមិត្តភក្តិនៅភ្នំពេញឈ្មោះ [redacted] សត្ថាវិត និងឈ្មោះ ស ដែលអាចជួយរត់ការឲ្យកូនអ្នកទាំងពីរចេញពីពន្ធនាគារបាន ហើយពេលនោះឈ្មោះ [redacted] មាស ជឿសំដីជនជាប់ចោទ បានប្រគល់ប្រាក់ដល់ជនជាប់ចោទជាបន្តបន្ទាប់ដោយមានប្រគល់ផ្ទាល់ដៃ វេរតាមធនាគារអេស៊ីលីដា និងវេរតាមផ្ទះជាលក្ខណៈឯកជន សរុបទាំងអស់៨០.០០០.០០០៛(សែសិបលានរៀល) តែក្រោយពីទទួលប្រាក់ហើយក្រុមជនជាប់ចោទមិនបានជួយដោះស្រាយរឿងកូនជនរងគ្រោះឲ្យចេញពីពន្ធនាគារទេ ហើយក៏មិនបានប្រគល់ប្រាក់ឲ្យជនរងគ្រោះវិញដែរ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០១(ង)ចុះថ្ងៃទី២៥-០២-២០១៤របស់សាលាដំបូងខេត្តស្វាយរៀងដែលមានខ្លឹមសារដូចតទៅ៖

១/ផ្តន្ទាទោសលើ ឈ្មោះ [redacted] លីថូ ភេទប្រុស អាយុ៥៥ឆ្នាំ និងឈ្មោះ [redacted] សត្ថាវិត ហៅ [redacted] សុជាវិទ្ធ ភេទប្រុស អាយុ៥៨ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០២ឆ្នាំ(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ដាក់ចូលថវិការដ្ឋក្នុងម្នាក់ៗចំនួន១.០០០.០០០(មួយលាន)រៀល ពីបទ ឆបោកប្រព្រឹត្តនៅភូមិក្រសាំង ឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង កាលពីថ្ងៃទី២៨-១០-២០១០។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២/ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើ ឈ្មោះ [redacted] សត្ថាវិត ហៅ [redacted] សុជាវិទ្ធ ភេទប្រុស អាយុ ៥៨ឆ្នាំ តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បង្គាប់ឲ្យឈ្មោះ [redacted] លីថូ និងឈ្មោះ [redacted] សត្ថាវិតហៅ [redacted] សុជាវិទ្ធ រួមគ្នាសងសំណងការខូចខាត និង ជម្ងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សរុបចំនួន ១០.០០០$ (មួយម៉ឺន)ដុល្លារអាមេរិក។ ការទាមទារលើសពីនេះសម្រេចច្រានចោល ។

៤-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១២-០២-២០១៤ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥-០២-២០១៤ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីថូ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សត្ថាវិត ។ សម្រេចបើកផ្លូវប្តឹងទាស់និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ១៩ ចុះថ្ងៃទី ២៥-០៣-២០១៤ របស់ ជនជាប់ ចោទឈ្មោះ [redacted] លីថូ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២៥-០២-២០១៤របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចទី១ និងទី ៣ នៃសាលក្រមនេះ ។

បានឃើញរបាយការណ៍ចុះថ្ងៃទី០៣-៧-២០១៤របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី០១-៨-២០១៤របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លីថូ បានឆ្លើយបញ្ជាក់ថា ខ្លួនប្តឹងឧទ្ធរណ៍មកមិនសុខចិត្តព្រោះមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ខ្លួនស្គាល់ជនរងគ្រោះឈ្មោះ [redacted] មាស ធ្លាប់បួសនៅវត្ត

ជាមួយគ្នា។ ក្រោយពីដឹងថា ជនរងគ្រោះចាញ់បោកឈ្មោះ [redacted] ម៉ាច ចំនួន១១.០០០$រឿងរត់ការដោះកូនគាត់នៅពន្ធនាគារខេត្តស្វាយរៀងនោះ ខ្លួនក៏និយាយប្រាប់គាត់ដូចចម្លើយខ្លួនឆ្លើយនៅសាលាដំបូងមែន ។ ខ្លួនពិតជាបានជូនឈ្មោះ [redacted] មាស វេរលុយឲ្យឈ្មោះស និងឈ្មោះ [redacted] សត្ថាវិត ម្តងមួយលាន ពីរលានរៀល ចំនួន១២លើកស្មើនឹងមួយម៉ឺនដុល្លាមែន តែខ្លួនមិនបានទទួលកំរៃក្នុងការជូនឈ្មោះ [redacted] មាស ទេ សំណូមពរសុំរួចផុតពីការចោទប្រកាន់ ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា ឈ្មោះ [redacted] លីថូ ក្រោយពីស៊ើបដឹងថា បងរបស់ខ្លួនឈ្មោះ [redacted] មាស ចាញ់បោកឈ្មោះម៉ាច រួចមកវាទៅនិយាយបញ្ចុះបញ្ចូលបងរបស់ខ្លួនថា៖ វាអាចទារលុយពីឈ្មោះម៉ាច ឲ្យគ្រប់ចំនួនវិញនិងជួយដោះកូនគាត់ឲ្យរួចពីគុក បងខ្លួនថាពុំមានលុយទេ ក្រោយមកវាទៅនិយាយពីរ បីដង ទើបបងលក់ផ្ទះ ដីស្រែ គោ ក្របី ប្រមូលលុយឲ្យវាអស់មួយម៉ឺនដុល្លាអាមេរិក សព្វថ្ងៃបងឈឺចិត្តស្លាប់ ខ្លួនធ្លាក់ខ្លួនក្រពុំមានផ្ទះ ដីនិងគោ ក្របីទៀតទេ ដោយចាញ់បោក [redacted] លីថូ ។សុំទាមទារដូចសាលាដំបូង

-តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន:

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ តែយោងតាមចំណារឯកឧត្តមអគ្គរងថា អំពើឆបោកបែបនេះមិនគួរសំរាលទោសទេ ព្រោះនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់ស្ថាប័នច្បាប់ ។ សុំសភាព្រហ្មទណ្ឌតម្កល់សាលក្រមសាលាដំបូងខេត្ត ទុកជាបានការ ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ១៩ ចុះថ្ងៃទី ២៥-០៣-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] លីថូ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ០១"ង" ចុះថ្ងៃទី២៥-០២-២០១៤ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចទី១ និងទី ៣ នៃសាលក្រម ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានឆ្លើយបដិសេធថា ពុំបានឆបោកប្រាក់ជនរងគ្រោះដែលជាដើមបណ្តឹងទេ។ ខ្លួនស្គាល់ជនរងគ្រោះឈ្មោះ [redacted] មាស ដោយធ្លាប់បួសនៅវត្តព្រហារជាមួយគ្នា។ក្នុងខែតុលាឆ្នាំ២០១៣ ខ្លួនត្រឡប់មកពីអូរបើជាន់បានទទួលពត៌មានថា ជនរងគ្រោះចាញ់បោកឈ្មោះហេងម៉ាច ចំនួន១១.០០០$ រឿងរត់ការដោះកូននៅពន្ធនាគារខេត្តស្វាយរៀង ។ ខ្លួនបានឲ្យលេខទូរស័ព្ទឈ្មោះស ទៅ [redacted] មាស ហើយនិយាយថា ខ្លួនមានស្គាល់គេនៅភ្នំពេញមានខ្នងធំ អាចជួយដោះកូនបានហើយក៏នាំជនរងគ្រោះមកភ្នំពេញជួបឈ្មោះស និង [redacted] សុជាវិទ្ធ ។ ឈ្មោះស និងជនរងគ្រោះ [redacted] មាស បានពិភាក្សាគ្នាខ្លួនពុំដឹងគេពិភាក្សារឿងអ្វីទេ បន្ទាប់ឈ្មោះ [redacted] មាសនិយាយប្រាប់ខ្លួនរយៈពេល២សប្តាហ៍ទៀត អាចជួយរត់ការបានលុយ១១.២០០$ ដែលចាញ់បោកគេនោះមកវិញ និងជួយដោះស្រាយកូនរបស់គាត់បានទៀត ។ ខ្លួនពិតជាបានជូនឈ្មោះ [redacted] មាស វេរលុយឲ្យឈ្មោះស និងឈ្មោះ [redacted] សុជាវិទ្ធ ម្តងមួយលាន ពីរលានរៀល ចំនួន១២ ៴

លើកស្មើនឹងមួយម៉ឺនដុល្លា ។ ពេលវេរលុយម្តងៗ ឈ្មោះស និង [redacted] សុជារិទ្ធ ឲ្យខ្លួនដកលុយនោះទុកមួយម៉ឺនទៅពីរម៉ឺនរៀលដើម្បីចាក់សាំង ។ ខ្លួនជូនជនរងគ្រោះទៅភ្នំពេញនិងជូនទៅវេរលុយដោយសារឈ្មោះ [redacted] វន់ សន្យាឲ្យខ្លួន៣០០$ ខ្លួនពុំដឹងថា ជនរងគ្រោះចាញ់បោកឈ្មោះស និង [redacted] សុជារិទ្ធ ហើយក៏ពុំជាប់ពាក់ពន្ធ័ដែរ ។

៣-តាមចម្លើយឲ្យការរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] បញ្ជាក់ថា ឈ្មោះ [redacted] លីថូ ក្រោយពីបានស៊ើបដឹងបងរបស់ខ្លួនឈ្មោះ [redacted] មាស ចាញ់បោកឈ្មោះម៉ាចរួចមកវាទៅនិយាយបញ្ចុះបញ្ចូលបងរបស់ខ្លួនថា៖ វាអាចទារលុយពីឈ្មោះម៉ាចឲ្យគ្រប់ចំនួនវិញ និងជួយដោះកូនបងខ្លួនឈ្មោះ [redacted] មាស ឲ្យរួចពីគុកបងខ្លួនថាពុំមានលុយទេ ក្រោយមកវាទៅនិយាយពីរ បីដង ទើបបងលក់ផ្ទះ ដីស្រែ គោ ក្របី ប្រមូលលុយឲ្យវាអស់មួយម៉ឺនដុល្លាអាមេរិក សព្វថ្ងៃបងឈឺចិត្តស្លាប់ ខ្លួនធ្លាក់ខ្លួនក្រពុំមានផ្ទះ ដីនិងគោ ក្របីទៀតទេ ដោយចាញ់បោក [redacted] លីថូ ។ សុំទាមទារដូចសាលាដំបូង ។

៤-ចម្លើយដោះសាររបស់ជនជាប់ចោទពុំមានភស្តុតាងដោះបន្ទុកតាមច្បាប់អាចឲ្យតុលាការជឿបានឡើយ ។ ប៉ុន្តែតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនិងស្តាប់ចម្លើយសាក្សីស៊ុំ គៀន ត្រូវជាប្រពន្ធជនរងគ្រោះឈ្មោះ [redacted] មាស បានបញ្ជាក់យ៉ាងច្បាស់ថា៖ ឈ្មោះ [redacted] លីថូ បានមកផ្ទះរបស់ខ្លួននិយាយលួងលោមខ្លួនថា គេអាចជួយទារប្រាក់ពីឈ្មោះម៉ាចដែលបានឆបោកខ្លួនចំនួន១១.២០០$ និង ជួយរត់ការដោះកូនឲ្យចេញពីពន្ធនាគារខេត្តស្វាយរៀង ដោយពុំចាំបាច់ចំណាយលុយទេ យន លីថូ បាននិយាយពីរ ទៅ បីដង ធ្វើឲ្យខ្លួននិងប្តីឈ្មោះ [redacted] មាស ជឿ ហើយយ៉ន លីថូ បាននាំគង់ មាស មកភ្នំពេញចំនួនពីរដងនិងឲ្យ [redacted] មាស រកប្រាក់វេរទៅភ្នំពេញជាច្រើនម្តង ១លានរៀល,ម្តង២លានរៀល វេរតាមធនាគារអេស៊ីលីដានិងវេរតាមផ្ទះឯកជនក៏មាន ដែលសរុបជាទឹកប្រាក់អស់១០.០០០$ ។ លុយដែលឈ្មោះម៉ាចបានយកថា រត់ការដោះកូនចំនួន១១.២០០$ក៏ទារពុំបាន កូននៅតែជាប់គុកដដែល ប្តីឈ្មោះ [redacted] មាស ឈឺចិត្តចាញ់បោកគេក៏បានឈឺស្លាប់ ។ ចម្លើយឲ្យការណ៍របស់ដើមបណ្តឹងនិងសាក្សីស៊ីសង្វាក់និងចម្លើយសារភាពខ្លះរបស់ជនជាប់ចោទ [redacted] លីថូ ខ្លួនពិតជាបានប្រាប់ឈ្មោះ [redacted] មាស ថាមានស្គាល់គេនៅភ្នំពេញមានខ្នងធំ អាចទារលុយពីឈ្មោះ ម៉ាច និង អាចជួយដោះកូនចេញពីគុកបានហើយក៏បាននាំជនរងគ្រោះទៅភ្នំពេញ ក្រោយមកក៏បានវេរលុយទៅភ្នំពេញ១២លើកសរុប១ម៉ឺនដុល្លាអាមេរិក ។ អំពើរបស់ជនជាប់ចោទមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសឆបោកគឺក្រោយពីជនជាប់ចោទបានដឹងថា ឈ្មោះ [redacted] មាស ចាញ់បោកឈ្មោះ ម៉ាច អស់ទឹកប្រាក់១១.២០០$ ខ្លួនក៏បានប្រើឧបាយកលទុច្ចរិតទៅនិយាយភូតកុហកជនរងគ្រោះ ដោយអះអាងថា ជួយទារលុយពីឈ្មោះម៉ាច មកឲ្យជនរងគ្រោះនិងជួយដោះកូនរបស់ [redacted] មាស ចេញពីគុកដោយមិនបាច់អស់ប្រាក់ទេ និងបានក្លែងឋានៈថា៖ មានស្គាល់អ្នកធំ បន្ទាប់ពីជនរងគ្រោះមានការជឿទុកចិត្តជនជាប់ចោទក៏នាំជនរងគ្រោះមកភ្នំពេញជួបបក្សពួករបស់ខ្លួនឈ្មោះស និងឈ្មោះ [redacted] សុជារិទ្ធ និយាយកុហកជនរងគ្រោះបន្ថែមដើម្បីទារប្រាក់ពីជនរងគ្រោះរហូតដល់ជនរងគ្រោះជឿហើយប្រគល់ឲ្យជនជាប់ចោទអស់១០.០០០$។

៥-សាលក្រមព្រហ្មទណ្ឌលេខ ៩១ ង ចុះថ្ងៃទី ២៥-០២-២០១៤ របស់សាលាដំបូងខេត្តស្វាយរៀងបានសម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសាលាឧទ្ធរណ៍តំកល់ទុកជាបានការដដែល ។

## ហេតុដូច្នេះសម្រេច

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ១៩ ចុះថ្ងៃទី ២៥-០៣-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] លីថូ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩ ចុះថ្ងៃទី ២៥-០៣-២០១៤ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខក្នុងច្បាប់កំណត់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះ អោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 11 ខែ 12 ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]